


# អារម្ភកថា

“មេឃបាត់ផ្លូវច័ន្ទ” ជាស្នាដៃដែលអ្នកនិពន្ធ ទី ជីហួត និទ្ទេសចំពោះជ័យជំនះជាប្រវត្តិសាស្ត្រដែលប្រជាជនទាំងបីប្រទេស កម្ពុជា វៀត-ណាម ឡាវ ដណ្តើមបានក្នុងការតស៊ូ រំដោះជាតិ ប្រឆាំងនឹងអាណានិគមនិយមបារាំង ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់បក្សកុម្មុយនិស្តឥណ្ឌូចិន និងចំពោះជ័យជំនះដ៏ធំធេងជាបន្តបន្ទាប់ ក្នុងការតស៊ូប្រឆាំងនឹងពួកចក្រពត្តិអាមេរិកឈ្លានពាន និងពួកក្រាលទីនិយមចិនប៉េកាំង ។

តាមរយៈស្នាដៃនេះ អ្នកនិពន្ធបានលាតត្រដាងជូនមិត្តអ្នកអានបានឃើញនូវស្មារតីលះបង់ខ្ពស់ នូវឆន្ទៈប្រយុទ្ធដ៏អង់អាចក្លាហាន និងចំណងសាមគ្គីភាព មិត្តភាព ជាពិសេសរវាងប្រជាជនទាំងបីប្រទេស នៅឥណ្ឌូ-ចិនដែលស៊ូស្លាប់រស់ជាមួយគ្នា ជួយឧបត្ថម្ភគ្នា ជ្រោមជ្រែងគ្នាទៅវិញទៅមក តាំងពីការលំបាកគ្រប់បែបយ៉ាង រហូតដល់ដណ្តើមបានជ័យជំនះជាស្ថាពរ ។

ឯករាជ្យ សេរីភាព ត្រូវដណ្តើមបានមកវិញ ប្រជាជនវៀតណាម

ឡាវ បានរស់នៅក្នុងសុខមង្គល ជួបជុំមូលត្រកូលគ្នាក្នុងគ្រួសារ និង កំពុងកសាងជីវភាពថ្មីក្នុងភាពជាម្ចាស់ប្រទេសជាតិ និង ជាម្ចាស់នៃជោគវាសនារបស់ខ្លួន ។

ប៉ុន្តែផ្ទុយទៅវិញ ប្រជាជនកម្ពុជា បែរជាត្រូវទទួលរងវិនាសកម្មយ៉ាងខ្លោចផ្សាបំផុត ។ ក្នុងរយៈពេលជាង ៣ ឆ្នាំ របបប្រល័យពូជសាសន៍ ប៉ុល ពត អៀង សារី ខៀវ សំផន ខ្ញុំកញ្ជះដាច់ថ្លៃរបស់ពួកវាតនិយមចិនប៉េកាំងបានសម្លាប់រង្គាលប្រជាជនកម្ពុជាអស់ជាង ៣ លាននាក់ ក្នុងនោះមានទាំងនារីជាសង្សាររបស់បូផាន់ ដែលជាតួអង្គក្នុងរឿងនេះផង ។

ផ្ទៃមេឃដ៏ធំល្វឹងល្វើយ ទោះបីលំអដោយតារារាប់លានដួង ក៏មិនមានសម្ផស្សស្មើ និង មានដួងចន្ទរះពេញបូរមីឡើយ ។ កំលោះទាំងឡាយតែងចាត់ទុកនារីជាទីស្រឡាញ់របស់ខ្លួន ដូចជាដួងចន្ទពេញបូរមីដែលរះក្នុងបេះដូងរបស់ខ្លួន ។

ចំពោះ បូផាន់ក៏ដូច្នោះដែរ ការនិរាសព្រាត់ប្រាសគូសង្សារដែលគេសង្ឃឹមថានឹងបានរៀបការជាមួយគ្នាក្រោយពេលដែលប្រទេសជាតិត្រូវបានរំដោះនោះ ប្រៀបបានទៅ នឹង មេឃដែលបាត់ដួងចន្ទ ។

នេះជាការសាកល្បងថ្មីមួយទៀតរបស់អ្នកនិពន្ធ ទី ជីហួត ក្នុងការតែងក្រងរឿងដែលមានទាក់ទងដល់ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ ។

ជាការពិត ស្នាដៃដ៏តូចនេះពុំអាចបកស្រាយឲ្យបានល្អិតល្អន់ សព្វជ្រុងជ្រោយនូវព្រឹត្តិការណ៍ ដែលបានកន្លងទៅរាប់សិបឆ្នាំហើយនោះទេ ហេតុដូច្នេះយើងខ្ញុំសូមមិត្តអ្នកអានទាំងឡាយ មេត្តាអធ្យាស្រ័យចំពោះចំណុចខ្វះខាតទាំងឡាយនោះ ។

យើងខ្ញុំសង្ឃឹមថាមិត្តអ្នកអាន នឹងជួយរិះគន់ស្ថាបនាចំពោះអ្នកនិពន្ធ និងចំពោះការបោះពុម្ពផ្សាយ ដើម្បីឲ្យការតែងនិពន្ធ និង ការបោះពុម្ពលើកក្រោយ បានកាន់តែល្អប្រសើរឡើង ។

អាគារបោះពុម្ពផ្សាយ វប្បធម៌

១

# អ្នកទោសនៅកោះត្រឡាច

ធាតុអាកាសនៅលើកោះត្រឡាច ពេលយប់ត្រជាក់ស្ទើរមុតឆ្អឹង ពេលថ្ងៃក្តៅស្ទើរខ្លោចស្បែក ។ ខ្ញុំត្រូវពួកបារាំងចាប់យកមកឃុំឃាំងនៅទីនេះ អស់រយៈពេលពីរឆ្នាំហើយ ។

នៅពីក្រោយខ្នង មានសុទ្ធតែព្រៃព្រឹក្សខ្ពស់ត្រដឹម ។ សម្លឹងទៅឆ្ងាយឃើញតែទឹកជាប់នឹងពពកមេឃ ប្រៀបបីដូចមហាសាគរដ៏ធំល្វឹងល្វើយនេះ គឺកំពុងតែលេចត្រចាក់ភ័ព្វយុវវ័យដ៏ស្រស់បំព្រងរបស់ខ្ញុំឲ្យលិចស្រិមទៅក្នុងភពខ្មៅងងឹតគួរស្តាយស្រណោះក្រៃលែង ។

នៅលើកោះទាំងមូល មានអ្នកទោសរាប់រយរាប់ពាន់នាក់ ចម្រុះសញ្ជាតិគ្នាទាំងបីប្រទេសគឺ កម្ពុជា វៀតណាម និង ឡាវ ចំណែកអ្នកទោសជាតិឡាវដូចខ្ញុំមានចំនួនតិចជាងគេ ។ ក្រោយពីការធ្វើទុក្ខបុកម្នេញរបស់ទាហានបារាំង រវាងអ្នកទោសនិងអ្នកទោសដូចគ្នា កើតជម្លោះទាស់ទែងគ្នាវិញទៅមក រហូតមានការវាយតប់កាប់សម្លាប់គ្នាស្ទើរតែរៀងរាល់ថ្ងៃ ។

ព្រឹកព្រហាមនៃថ្ងៃមួយ ពេលដែលសំឡេងមាន់រងាវកាន់តែស្ញៀយ

ទៅហើយនោះ ខ្ញុំរំភើបតាមបង្អួចទ្វារគុក សម្លឹងទៅទិសខាងកើត ដើម្បី
ផ្ដិតយកសោភ័ណភាពរបស់ផ្ទៃមេឃ នៃអរុណោទ័យ ។

ព្រះអាទិត្យរះបំភ្លឺផែនដីទៀងទាត់ពេលវេលាជានិច្ច ប៉ុន្តែសិទ្ធិសេរីភាពរបស់អ្នកទោសនយោបាយ ហាក់ដូចជាធ្លាក់ចុះទៅក្នុងបាតសមុទ្រ បាត់ស្រមោលឈឹង ។

ខណៈដែលខ្ញុំកំពុងតែស្ទុះអារម្មណ៍នៅក្នុងក្ដីអស់សង្ឃឹមយ៉ាងល្វ ចាប់តែម្នាក់ឯងនោះ ស្រាប់តែមានបាតដៃមួយមកប៉ះស្មាស្រាលៗ ជាមួយ នឹង វាចាទន់ភ្លន់ ៖

— ឬបងឯងកំពុងគិតអីហ្នឹង ?...

ខ្ញុំងាកក្រោយ ឃើញមិត្តភ័ក្ដិ ដែលជាជនជាតិខ្មែរស្និទ្ធស្នាល ជាក់ជាមួយ នឹង ពន្លឺភ្នែកស្លូតបូត ។ មិត្តភ័ក្ដិសំដែងអាការៈភាពភិតភាស្ញប់ចំពោះខ្ញុំ ក៏ប៉ុន្តែគេហាក់ដូចជាភ្លេចគិតដល់ខ្លួនគេ ព្រោះគេក៏ជាអ្នកទោសវ័យក្មេងដូចខ្ញុំដែរ ។

ខ្ញុំញញឹមស្ងួតដាក់មិត្ត ដោយគ្មានឆ្លើយតបមួយម៉ាត់ រំពេចនោះ លោមិត្តត្រឹងដែលជាជនជាតិ វៀតណាម ដើរសំដៅមកកាន់យើងទាំងពីរនាក់ទាំងសើចទន់ឡន់ ហើយពោលឡើងថា ៗ ៖

— ម៉ោយវ៉ា ត្រលឹមឡើងពួកពោះចង់ជាប់ពោះវៀន ចើតែយ៉ាងហ្នឹងរស់មិនបានយូរប៉ុន្មានទេ !..

មិត្តភ័ក្ដិងាកទៅនិយាយជាភាសាវៀតណាម ៖

— ហ៊ឺ ... ធ្វើម៉េចទេ ត្រឹងអើយទ្រាំសិនទៅ !



ត្រឹងសំដែងអាការៈក្ដៅក្រហាយ ៖

— ហ៊ឺះ !.. តើពួកយើងទ្រាំសុខនៅរស់ចាំស្លាប់ដល់ពេលណាទៀត !.. ខ្ញុំសម្លឹងមុខត្រឹងបន្តិច ទើបបន្តឆ្លើយចំផ្ចួរខ្ញុំមួល ៖

— នៅជុំវិញកោះ សុទ្ធតែទឹកសមុទ្រល្ហល្ហេ! រីឯពួកយើងមានតែបាតដៃទទេចុះណ្ហោះ តើឲ្យធ្វើម៉េចទៅ !...

— ក៏សាកណាស់ ខ្ញុំចង្អល់ចិត្តណាស់ហើយ គ្មានទេណាព្រមសោះ ទោះបីយ៉ាងណាក៏ដោយ ក៏ពួកយើងត្រូវតែតស៊ូបន្តជីវិតឲ្យឃើញសន្តោសដែរ !

ការតស៊ូ ក៏យើងត្រូវចេះរើសពេលវេលាដែរ ( មិត្តចិន្តគប )

ត្រឹងក្ដាប់ដៃ ពើតភ្នែកក្រឡោត ៖

— ខ្ញុំជាប់គុកនៅលើកោះនេះជាងមួយឆ្នាំមកហើយ តើយើងត្រូវរង់ចាំដល់ពេលណាទៀត ឬមួយក៏ចាំទាល់តែម្នាក់ ៗ ចាស់សក់ស្កូវ ខ្នងកោងទៅ !...

ខណៈ ដែលបរិយាកាស នៃការសន្ទនារបស់យើងកំពុងតែអាប់អួនោះ ស្រាប់តែមានសំឡេងមនុស្សម្នាក់លូកមាត់ឆ្លើយមកពីចម្ងាយ ៖

— ក្មួយ ៗ ទាំងអស់គ្នាកុំអន្ទះសារពេក ត្រូវចាំឱកាសនៅថ្ងៃស្ពាយក្រោយណា !.. យើងទាំងអស់គ្នាងាកទៅ ឃើញម្ចាស់សំដីជាបុរសចំណាស់ម្នាក់ ឈ្មោះតួនដែលមានពុកមាត់ស្រមូម អង្គុយបែនភ្នែនស្នែកខ្នងទៅនឹងជញ្ជាំងគុក ក្នុងសភាពជាមនុស្សមានចរិតនឹងនស្ងប់ស្ងៀមយ៉ាងជម្រៅ ។ គាត់ជាជនជាតិខ្មែរ ដែលត្រូវបារាំងចាប់យកមកឃុំឃាំងនៅ

លើកោះត្រឡាចនេះ តាំងពីយូរមកហើយ ។ ចុះបើយាត់និយាយ ប៉ុន្តែគាត់បែរមុខទៅទិសផ្សេង ឥតរវល់ងាកមើលពួកយើងទៀយ ។

ត្រឹងឧទានទាំងក្តៅក្រហាយ ៖

- ហ៊ឺះ ! . . . មិនឲ្យអន្ទះសា ! . . .

- ខ្ញុំជាប់ឃុំនៅលើកោះនេះអស់រយៈពេលជាងដប់ឆ្នាំមកហើយ ។ រីឯពួកក្មួយទើបតែនឹងមកជាប់ក្រោយសោះ ហេតុអ្វីក៏ទ្រាំពុំបាន ( ពួងពោលដោយភាពទឹកទន់ភ្លន់ )

ត្រឹងស្រែកតឹងសរសៃក ៖

- ចង់ឲ្យពួកយើងធ្វើពុតកំសាករហូតឬ ? . . . មកពីធ្វើការវិញ មួយថ្ងៃៗ ឃើញតែពួនអង្គុយសញ្ជប់សញ្ជឹងស្ងៀមស្ងាត់ ! . . ហ៊ឺះ!.. ទីនេះជាគុករបស់បារាំងណា៎ មិនមែនជាព្រះវិហារសម្រាប់ការទានធម៌ទេ !... ខ្ញុំភ័យព្រួយ ព្រោះនឹកឃើញថា ពួងមុខជាខឹងនឹងពាក្យសំដីរបស់ត្រឹងជាមិនខាន នឹងអីគាត់បែរជាងាកមកញញឹមដាក់ ហើយពោលពន្យល់មួយៗ ៖

- ក្មួយៗ អើនេះ យើងធ្វើស្រែ នៅពេលស្រូវពុំទាន់ទុំផង បើយើងច្រូតកាត់មក វាមិនខូចខាតឥតអំពើទៅហើយ ? ដូច្នេះទោះបីយើងមានសេចក្តីព្យាយាមប៉ុនណាក៏ដោយ សកម្មភាពរបស់យើងក៏ត្រូវតែអនុវត្តឲ្យសមស្របពេលវេលាដែរ . . .

ត្រឹងលើកស្មែកចិៗ ៖

- យី ពួងចង់និយាយពីអ្វីហ្នឹង ! ( ព្រោះពួងនិយាយភាសា



វៀតណាមពុំសូវច្បាស់ )

- ក្មួយៗ ទាំងអស់គ្នា ត្រូវគេចាប់យកមកដាក់គុកនៅកោះត្រឡាចនេះ ព្រោះតែពួកក្មួយលះបង់ខ្លួន ដោយចូលរួមក្នុងចលនាបដិវត្តដើម្បីរំដោះប្រទេសជាតិ ។

- អ្នកណាថា ខ្ញុំធ្វើបដិវត្តន៍ ! ( ត្រឹងប្រកែកញ៉ាញ៉ា )

ទ្រាំពុំបាន ខ្ញុំលូកមាត់ចូល ៖

- ត្រឹងកុំមាត់ឡូឡាពេក ចាំស្តាប់ពូនិយាយឲ្យអស់សិន !

ពួងងាកសម្លឹងមុខខ្ញុំ ហើយពោលបន្ត ៖

- កម្លាំងបដិវត្តរបស់ប្រជាជនទាំងបីប្រទេសនៅឥណ្ឌូចិន កំពុងតែពុសពុលគ្រប់ទីកន្លែងហើយ ។ ពេលនេះ ពួកយើងត្រូវរងគ្រោះដោយសារបារាំងចាប់យកមកដាក់គុក ធ្វើបាបមែន ប៉ុន្តែឆន្ទៈរបស់យើងនៅតែមុតស្រួចជានិច្ចក្នុងទិសដៅរំដោះ ប្រទេសជាតិពីនឹមអាណានិគមនិយមបារាំង ។ ដូច្នេះ បើពុំទាន់ទាល់ច្រកទេ ក្មួយៗ ទាំងអស់គ្នា ត្រូវសង្ងំស្ងៀមសិន ព្រោះត្រូវតែថែរក្សាជីវិតឲ្យបានរស់រាន រង់ចាំពេលវេលាថ្មីមកដល់ ដើម្បីចូលរួមក្នុងចលនាតស៊ូតទៅទៀត ។ បើសិនជាយើងប្រឆាំងនឹងវាទៅពេលនេះ គឺចំណេញតែស្លាប់ខ្លួនឥតអំពើទេ ! . . . បុរសចំណាស់និយាយចប់ ចន្ទដើរចូលទៅជិតពោលពាក្យសុភាពរាបសាជាភាសាកម្ពុជា ៖

- ហេតុតែបានជាពូ និយាយថា ពួកខ្ញុំជាអ្នកបដិវត្ត បើឮដល់ពួកបារាំងមិនរួចនោះហើយ . . .

- ក្មួយចង់ ស្មានថាពូមិនដឹងអ្វី ! ពួកបារាំងបានវាយសួរចម្លើយក្មួយជាច្រើនលើកច្រើនសា ប៉ុន្តែក្មួយមិនព្រមសារភាពថា ក្មួយជាជនឥស្សរៈសោះ ទាំងក្មួយបូជាន់ក៏ដូចគ្នា អត់ព្រមឆ្លើយថា ជាសមាជិកចលនាឥស្សរៈឡើយទេ ។ តើពូនិយាយនេះត្រូវឬទេ ?

ពូនិយាយដល់ឈ្មោះខ្ញុំ ត្រឹមជាក់សម្ដីមុខខ្ញុំ ហាក់ចង់ស្ទាបស្ទង់ថា តើខ្ញុំជាជនឥស្សរៈឡើងមែនឬ ? . . . តាមការពិត ដោយជាប់ឃុំក្នុងគុកជាមួយគ្នារាប់ខែមកហើយ ពួកអ្នកទោសទាំងអស់ច្រើនតែរៀនភាសាពីគ្នាទៅវិញទៅមក ដូច្នេះ ទោះជាអ្នកខ្ជិលច្រអូសយ៉ាងណាក៏គង់តែអាចនិយាយ អាចស្ដាប់ភាសាគេទៀត ដែលក្រៅពីភាសាជាតិរបស់ខ្លួនបានខ្លះៗ ដែរ ។

ខ្ញុំធ្វើជាមិនដឹងខ្លួន ហើយងាកទៅសួរពូភ្នង ៖

- សំអាងលើអ្វី បានជាលោកពូថាខ្ញុំជាជនឥស្សរៈ ?

បុរសចំណាស់សើចទឹក ៖

- ពូក្មួយកុំព្រួយបារម្ភឲ្យសោះ មិនបាច់លាក់បាំងនឹងពូទេ ព្រោះពូក៏ជាអ្នកតស៊ូម្នាក់ដែរនៅកម្ពុជា ទើបត្រូវពួកបារាំងវាចាប់យកមកដាក់គុកនៅលើកោះនេះ ! . . .

- ឈប់និយាយគ្នា ! . . . ( ត្រឹងស្រែកយ៉ាងរហ័ស ហើយចូញមាត់ទៅក្រៅគុក )

ទាំងអស់គ្នាបាត់មាត់ឈឹង ហើយងាកមើលតាម ឃើញនាយទាហានបារាំងម្នាក់ដើរបណ្ដើរគ្នាជាមួយឧត្ដមសេនីយ៍វៀតណាម ឈ្មោះ



សិន ដែលជាអ្នកគ្រប់គ្រងកោះត្រឡាចសំដៅមក ។

លុះមកដល់ពីមុខទ្វារ ទាហានម្នាក់ដែលជាអ្នកយាមគុក ស្ទាយកាំភ្លើងដើមកវាយកែងជើងទាច់ផ្ទុង ! . . ឧត្ដមសេនីយ៍សិន និយាយទៅមួយភ្លែត ស្រាប់តែឃើញទាហានយាមចាក់សោរបើកទ្វារ ។

នាយទាហានបារាំងនិងឧត្ដមសេនីយ៍វៀតណាម ដើរចូលមកត្រួតមើលអ្នកទោសក្នុងគុកយ៉ាងពិនិត្យពិច័យ ទើបដើរចេញទៅក្រៅវិញសួរអ្នកយាម ៖

- គុកលេខ ២៤ នេះ មានអ្នកទោសក្មេងៗ អាយុចាប់ពីម្ភៃឆ្នាំចុះក្រោមចំនួនប៉ុន្មាននាក់ ?

អ្នកយាមបើកសៀវភៅមើលញាប់ដៃ មួយសន្ទុះទើបឆ្លើយ ៖

- បាទ ! ដប់ប្រាំពីរនាក់បាន !

ឧត្ដមសេនីយ៍សិន បកប្រែពិគ្រោះជាមួយនឹងទាហានបារាំងបន្តិច ទើបងាកមកបញ្ជា ៖

- បញ្ចេញអ្នកទោសចាស់ៗ ទៅធ្វើការដូចធម្មតា ឯអ្នកទោសក្មេងៗ អាយុចុះពីម្ភៃឆ្នាំ ត្រូវបញ្ជូនទៅការិយាល័យកណ្ដាល ដើម្បីរៀបចំដំណើរឡើងកប៉ាល់នាំយកទៅកាត់ទោសសាជាថ្មីម្ដងទៀត !

អ្នកយាមបើកភ្នែកធំៗ សួរបញ្ជាក់ ៖

- យកទៅកាត់ទោសម្ដងទៀត ?

- អឺ ! ( សិនងក់ក្បាល ដៃច្រត់ចង្កេះយោរស្រែងយ៉ាងសង្ហា )

ពាក្យសន្ទនារវាងឧត្ដមសេនីយ៍គ្រប់គ្រងកោះត្រឡាច និងសហ-

ការីរបស់គេ ខ្ញុំស្គាល់ពួកទាំងអស់គ្នានោះចាត់មួយចាត់ឡើយ ។ ហេតុការណ៍ដែលឲ្យនេះធ្វើឲ្យខ្ញុំត្រេកអរស្ញើរកើតឡើងពីថា ព្រោះឆ្នាំនេះខ្ញុំទើបតែនឹងអាយុដប់ប្រាំបួនឆ្នាំប៉ុណ្ណោះ ។

ស៊ីន សប៊ីងអ្នកទោសក្នុងគុកមួយគ្រួសទៀត ទើបតាក់និយាយជាមួយអ្នកយាម ៖

- ប្រជាជនកើតប្រឆាំងគ្រប់ទីកន្លែងទាំងអស់ ក្នុងប្រទេសទាំងពីឥណ្ឌូចិនយើង ។ អ្នកទោសនយោបាយដែលចាប់បានបញ្ជូនមកកាន់ទីនេះ កើតចំនួនកាន់តែច្រើនឡើង ។ ដូច្នេះហើយបានជាថ្នាក់លើកប្រឲ្យនាំយកអ្នកទោសវ័យក្មេង ៗ ទៅធ្វើការកាត់ទោសសាជាថ្មី ឯងចាត់ចែងឲ្យបានរហ័សណាស់ . . .

- ប្របាទម្ចាស់ . . . ( អ្នកយាមតបទាំងទទួលបញ្ជា )

គ្រាន់តែខ្មួលសេនីយ៍ស៊ីន និងនាយទាហានបារាំងដើរចេញផុតទាយគុកក៏បើកបញ្ជីឈ្មោះអ្នកទោស ហើយហៅប្រមូលគ្នាមកចាត់ចែងតាមបញ្ជាទៅហ្វូងឆ្ងាយ ។

ពួកខ្ញុំ និង អ្នកទោសចាស់ ៗ ឯទៀត ។ ត្រូវគេបើកទ្វារបញ្ចេញឲ្យទៅធ្វើការជួសជុលផង ។ មុននឹងដើរចេញ ពួកក្បៀតលួចផ្តាំផ្ញើមិត្តចិន្ត ដែលជាជនជាតិខ្មែរដូចគ្នា ៖

- ក្មួយចិន្ត ទំពាំងស្នងឫស្សី កុលបុត្រប្រុស ស្រីស្នងជាតិ ។ សព្វថ្ងៃនេះ ក្មួយគឺជាទំពាំងស្នងឫស្សីដែលទើបនឹងដុះចេញផុតពីដី ដូច្នេះក្មួយកុំភ្លេចកាតព្វកិច្ចរបស់ក្មួយដែលជាសសរទ្រូងរបស់ប្រទេសជាតិឲ្យសោះ ។



បើសិនជាពួកត្រូវរស់ជីវិតនៅលើកោះនេះ ពួកសុំផ្ញើសេចក្តីសង្ឃឹមលើក្មួយៗជាមនុស្សជំនាន់ក្រោយនេះហើយ ដែលជាអ្នកបន្តវេនបដិវត្តក្នុងការរំដោះប្រទេសជាតិមាតុភូមិពីនឹមត្រួតត្រារបស់អាណានិគមនិយមបារាំង ។ ខ្នោះរបស់ពួកវា អាចដាក់លើជើងរបស់យើងបាន ប៉ុន្តែពុំអាចដាក់ចិត្តយើងជាប់ទេ ! . . .

ពេលចប់ គាត់ញញឹមស្ងួតសម្លឹងមុខចិន្ត ខ្ញុំ និង ត្រឹងជាសញ្ញាលាគ្នាជាចុងក្រោយ ទើបអូសជើងដើរចេញតាមអ្នកទោសឯទៀតទៅ ។

ខ្ញុំនឹករំភើបក្នុងចិត្តជាខ្លាំង ចំពោះពាក្យសំដីទូន្មានប្រកបដោយខ្លឹមសាររបស់ពូក្តួង ។ មិត្តត្រឹងដែលធ្លាប់តែមានចរិតរពិសរពើ ពេលនេះក៏មានអាកប្បកិរិយាស្រងូតស្រងាត់ខុសពីធម្មតាដែរ ។

នៅពេលឡើងកប៉ាល់ធ្វើដំណើរទៅកាន់ដីគោក ខ្ញុំ និង ចិន្តត្រូវបែកពីត្រឹង ព្រោះអ្នកទោសជាតិវៀតណាម ត្រូវជិះកប៉ាល់ទៅឲ្យគេកាត់ទោសនៅទីក្រុងព្រៃនគរ ។

ចំណែកអ្នកទោសវ័យក្មេងជាតិខ្មែរ និង ឡាវ ត្រូវជិះកប៉ាល់ផ្សេងទៅកាន់ក្រុងភ្នំពេញ ។

ខ្ញុំ និង ចិន្តនឹកមិត្តត្រឹងសោកស្តាយនឹងការព្រាត់ប្រាស លាយឡំដោយការសប្បាយរីករាយផង ព្រោះម្នាក់ៗ សង្ឃឹមថា នឹងបានជាន់ដីគោកវិញហើយ ។

* *

*

# ២

## រសាត់ជួបចក

នៅក្នុងគុកធំភ្នំពេញ ខ្ញុំត្រូវបែកពីមិត្តថ្មីទៀត ព្រោះគេយកអ្នកទោសដែលមកពីកោះត្រឡាច ទៅបញ្ចូលក្នុងបន្ទប់ធំនាជាមួយនឹងអ្នកទោសចាស់ដែលមានពីមុនមកស្រាប់ ។

ពេលយប់មកដល់ មូសរោមខាំដូចគេបាចអង្ការ ណាមួយរលាផងធ្វើឱ្យខ្ញុំដេកពុំលក់សោះ ។ អ្នកទោសជាតិខ្មែរ មានអ្នកខ្លះគេមានបងប្អូនរបស់គេយកម្ហូបយកមុងមកឱ្យ រីឯខ្ញុំវិញ តើមានបងប្អូនឯណានឹងគេ បើស្រុកកំណើតរបស់ខ្ញុំនៅឆ្ងាយម្ល៉េះ ... ហើយគ្មានអ្នកណាដឹងថា ខ្ញុំត្រូវមកជាប់គុកនៅទីនេះផង ។ កុំថាឡើយដល់ទៅមុងមួយ សូម្បីតែសំលៀកបំពាក់ ក៏មានតែមួយចង្កេះរហែករហៃដែរ ។

ល្ងាចមួយនោះ ពេលព្រលប់ទៅហើយ ក្នុងពេលដែលខ្ញុំកំពុងតែដេកស្រណោះខ្លួនយ៉ាងស្ងៀមស្ងាត់ ស្រាប់តែមានបង្វេចមួយហើរមកត្រូវខ្លួនចំពីមុខ ។ លុះខ្ញុំងាកទៅ ឃើញនារីតប្រូតម្នាក់ឈរញញឹមនៅពីក្រៅទ្វារដែក ហើយរាវៃពោលជាភាសាកុកជាតិថា ៗ៖

– កុំនិយាយប្រាប់គេ ...



ពោលពុតពីមាត់ នាងដើរចេញទៅបាត់ភ្លាម ។ ពាក្យសំដីរបស់នាងខ្ញីបែន ប៉ុន្តែតាមអាកប្បកិរិយានិងពន្លឺភ្នែក អាចឱ្យដឹងថា នាងប្រគល់បង្វេចនេះឱ្យខ្ញុំ ។

មិនបង្អង់យូរ ខ្ញុំស្រាយបង្វេចមើលភ្លាម ហើយរំភើបត្រេកអរជាខ្លាំង ព្រោះមិននឹកស្មានថា ហេតុយ៉ាងណាបានជានារីតប្រូតមានចិត្តសប្បុរសដល់ម្លឹង ។ តាមការពិត តប្រូតនេះមានអាយុខ្ទង់សាមសិបឆ្នាំ គាត់ជាអ្នកត្រួតពិនិត្យ និង នាំអ្នកទោសក្នុងបន្ទប់ខ្ញុំធ្វើការងារជារឿយ ៗ ដូច្នេះហើយបានជារឿងដែលខ្ញុំកំពុងត្រូវការចាំបាច់ជាទីបំផុតនោះ ត្រូវបានគាត់យល់ និងដឹង រួចផ្តល់ឱ្យសព្វគ្រប់ទាំងអស់ ។

នៅក្នុងបង្វេចក្រមានោះមានខោអាវមួយសំរាប់ ។ របស់អស់ទាំងនេះ សុទ្ធតែជំនិ មិនមែនថ្មីស្រឡាងទេ ប៉ុន្តែចំពោះអ្នកទោសដែលកំពុងជាប់ក្នុងមន្ទីរឃុំឃាំងដូចខ្ញុំ វាមានតំលៃលើសគ្រឿងអលង្ការពស្ត្រារបស់ស្តេចផែនដីទៅទៀត ។

ខ្ញុំស្រវាអាហារយកមកហូបដោយសប្បាយរីករាយតែម្នាក់ឯង។ពេលនេះ ទើបខ្ញុំចាប់ផ្តើមរំលឹកឡើងវិញចំពោះអាកប្បកិរិយារបស់នារីតប្រូត ។ ថ្វីបើមានតួនាទីក្នុងកងកម្លាំង ប៉ុន្តែគាត់នៅតែមានអត្តចរិតដូចនារីកម្ពុជាឯទៀតដែរ គឺស្លូតបូតនិងទន់ភ្លន់គួរឱ្យស្រឡាញ់ ។ គាត់ដឹងថាខ្ញុំចេះភាសាកុកជាតិតែបន្តិចបន្តួច ដូច្នេះ មានពេលខ្លះ គាត់ត្រូវបង្ហាត់បង្ហាញខ្ញុំ ដោយប្រើកាយវិការពន្យល់ជាមួយនឹងសំដីផង ហើយពុំដែលសម្លុតគំរាមកំហែងសោះ ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ខ្ញុំមិន

និកស្មានដល់ទាល់តែសោះថា គាត់មានចិត្តធម៌ករុណាគាំទ្រខ្ញុំរហូតដល់ល្មមផ្តល់សំលៀកបំពាក់ដោយស្ម័គ្រចិត្តយ៉ាងនេះទេ ។

ខ្ញុំលាអាវពាក់ពីលើអាវចាស់មួយជាន់ទៀត ហើយដណ្តប់ក្រមាថែម ទើបចូលព្រួតខ្លួនផ្អែកទៅនឹងជញ្ជាំង គិតស្រមៃទៅស្រមោលអតីតកាលដ៏ជូរចត់ដែលកន្លងផុត ។ ឃើញអាកប្បកិរិយាស្លូតបូតសុភាពរាបសាររបស់នារីក្រមុំ ធ្វើឲ្យខ្ញុំនឹកដល់បងប្អូនដែលនៅឯប្រទេសឡាវ ។

ខ្ញុំជាជនជាតិភូថៃ នៅខេត្តសេកុង ជាប់ព្រំប្រទល់ប្រទេសឡាវនិងវៀតណាម ។ ឪពុករបស់ខ្ញុំជាកសិករក្រីក្រ ហើយមានកូនច្រើននាក់នៅក្នុងបន្ទុក ។ ពេលដែលខ្ញុំរៀនចប់ថ្នាក់ទាបបឋមសិក្សា ហើយដើម្បីនឹងបន្តការសិក្សាតទៅទៀត ខ្ញុំត្រូវទៅរៀននៅទីក្រុងវៀងច័ន្ទ ។ ប៉ុន្តែការធ្វើដំណើរពីខេត្តសេកុងទៅវៀងច័ន្ទ ត្រូវចំណាយពេលដល់ទៅពីរសប្តាហ៍ ណាមួយក្នុងមហាហួសថ្លៃ ទាមទារសោហ៊ុយសោធារច្រើនពេក ឪពុកខ្ញុំ ក៏សំរេចចិត្តបញ្ជូនខ្ញុំឲ្យទៅរៀននៅទីក្រុងហ្វេ ប្រទេសវៀតណាម ព្រោះការធ្វើដំណើរផ្លូវជិត ហើយងាយស្រួលជាងទៅវៀងច័ន្ទ ។

ខ្ញុំលាចាកគ្រួសារ ធ្វើដំណើរតាមរថយន្តទៅដល់ដុងហា ទើបឡើងជិះរទេះភ្លើងបន្តដំណើរទៅដល់ហ្វេ ។

ក្នុងមហាវិទ្យាល័យនៅក្រុងហ្វេ មាននិស្សិតជាតិវៀតណាម កម្ពុជា ឡាវ និងថៃនៅសិក្សាចំរុះគ្នា ។



កាលនោះមានចលនាបដិវត្ត បានផ្ទុះឡើងនៅប្រទេសវៀតណាម ប៉ុន្តែខ្ញុំពុំទាន់យល់សោះថា បដិវត្តន៍នោះជាអ្វីទេ ។

លុះដល់ឆ្នាំ មួយពាន់ប្រាំបួនរយសែសិបប្រាំ ពេលដែលចលនាតស៊ូរីករាលដាលស្ទើរតែពេញប្រទេសទាំងបីនៅឥណ្ឌូចិននោះ ខ្ញុំក៏វិលត្រឡប់មកស្រុកកំណើតវិញ ។

ក្រោយមក អាណានិគមនិយមបារាំងចាញ់សង្គ្រាម ដកទ័ពថយចេញពីឥណ្ឌូចិន ប៉ុន្តែពួកហ្វាស៊ីសជប៉ុនក៏ចូលមកលុកលុយ ទន្ទ្រានទីនៅតំបន់នេះម្តង ។

ភ្លើងសង្គ្រាមកាន់តែឆាបឆេះសន្ធោសន្ធៅ ព្រោះប្រជាជនវៀត-ណាម កម្ពុជា និង ឡាវបានក្រោកឡើងតស៊ូយ៉ាងផុសផុលស្ទើរគ្រប់ទីកន្លែង ក្នុងគោលដៅរួមគ្នា គឺរំដោះប្រទេសជាតិរៀងៗខ្លួនចេញពីនឹមត្រួតត្រារបស់ជប៉ុន ។

ដោយឈឺចាប់ចំពោះអំពើឈ្លានពានរបស់បរទេស ហើយនឹកអាសូរចំពោះសភាពមាតុភូមិ ខ្ញុំក៏ចាប់ផ្តើមស្គាល់ពីកាតព្វកិច្ចរបស់ខ្លួនជាពលរដ្ឋម្នាក់ ។ ខ្ញុំបានយល់ជ្រួតជ្រាបពីមាគ៌ាបដិវត្តន៍ និង លទ្ធិម៉ាក្សលេនីនបន្តិចម្តងៗ ។ ទីបំផុតឆ្នាំមួយនោះ ខ្ញុំក៏សំរេចចិត្តចូលបំរើក្នុងចលនាឥស្សរៈឡាវ ដើម្បីរួមចំណែកក្នុងការរំដោះប្រទេសជាតិ ។

ធ្វើការតស៊ូក្នុងតំបន់ភ្នំវ៉ែងប្រមាណជាប្រហែលប្រាំមួយខែ ខ្ញុំត្រូវគេចាត់តាំង ឲ្យទៅចូលបំរើការងារក្នុងក្រុមឃោសនាប្រដាប់អាវុធ ដើម្បីបំផុសចលនាប្រជាជន ។

អាណាចិត្តបន្តិចដោយបានរំដោះកក់ចេញពីសណ្ដានចិត្តមួយរយៈ ។ លុះពេលជប៉ុនត្រូវចាញ់សង្គ្រាមលោកលើកទីពីរ ហើយជនជាតិបារាំងត្រឡប់ទៅស្រុកវិញ បារាំងក៏វិលត្រឡប់ចូលភូមិភាគនេះម្តងទៀត ។ ប៉ុន្តែប្រជាជននៃប្រទេសទាំងបី ។ ក្រោយការដឹកនាំរបស់បក្សកុម្មុយនិស្តឥណ្ឌូចិន នៅតែបន្តការតស៊ូយ៉ាងសកម្មក្លាហានដើម្បីទាមទារឯករាជ្យ ។

ថែមទៀតគ្រាន់ ឆ្នាំមួយនោះក្នុងរដូវវស្សា ខ្ញុំត្រូវពួកបារាំងចាប់ខ្លួនបានទៅក្នុងគុកមួយរយៈហើយបញ្ជូនមកភ្នំពេញ ទើបបញ្ជូនបន្តទៅដាក់ឃុំឃាំងនៅលើកោះត្រឡាចអស់រយៈពីរឆ្នាំ ។

ដូចពាក្យសំដីរបស់កូនចិញ្ចឹមនៅក្នុងគុក នាព្រឹកព្រលឹមមុនពេលបែកគ្នានោះពុំខុសទេ គឺក្នុងរយៈពេលជាប់ឃុំលើកោះត្រឡាច រាល់ពេលដែលពួកវាសួរចម្លើយ ខ្ញុំតែងតែប្រកែកជានិច្ចថា ខ្ញុំមិនមែនជាជនសង្ស័យឡើយទេ នោះមិនត្រូវពួកវាវាយធ្វើបាប ឬក៏សម្លុតគំរាមកំហែង និង ចោទបញ្ហាតម្រៀបតាក់ដោយ ។

លុះមកដល់ពេលនេះ ក្នុងចិត្តខ្ញុំលែងមានសេចក្ដីសង្ស័យខ្លះ ។ ហើយថា និងបានរួចពីទុក្ខទោស ព្រោះដឹងថា ពួកបារាំងដែលដឹកនាំអ្នកទោសរួមគ្នាមកកាត់ទោសសាជាថ្មីម្ដងទៀត ព្រោះនៅលើកោះត្រឡាច អ្នកទោសនយោបាយភាគច្រើនកើតជំងឺរបេងរាគរូសត្រូវទទួលទោសល្មម ។ ប្រហែលជាត្រូវគេដោះលែង ។

ក្នុងខណៈដែលកំពុងតែស្ងប់អារម្មណ៍ នៅក្នុងស្រមោលនឹកគិតការនោះ ស្រាប់តែខ្ញុំត្រូវគេកាត់ក្រើត ដោយត្រូវភ្ញាក់ងារតម្រួតគុកចាប់រុញច្រានចូលក្នុងគុកងងឹត ដើម្បីដាក់ខ្នោះជើង ។ យប់នេះ ខ្ញុំដេកលក់ពុំស្កប់ ព្រោះត្រូវស្រម៉ៃពាក់សព្វផង ព្រោះមានមួយដណ្ដប់ ធ្វើឱ្យខ្ញុំងងុយមិនគេចពីពោះពីតចិត្តសាប្រសារបស់ទាហានប្រុសនោះ ។

នៅក្នុងគុកភ្នំពេញនេះ មានតែរូបខ្ញុំម្នាក់គត់ដែលជាអ្នកទោសជាតិឡាវ ព្រោះអ្នកនោះសុទ្ធតែជាតិកម្ពុជាឯទៀតអស់ ។

រៀងរាល់ថ្ងៃសីល គេតែងតែនិមន្តព្រះសង្ឃមកសូត្រធម៌ និងទេស-នាប្រដៅទូន្មានអ្នកទោស ។ កិច្ចការនេះ ខ្ញុំយល់ច្បាស់ណាស់គឺជាកលល្បិចរបស់ពួករាជការខ្មែរ សក្តិភូមិដែលយកសាសនាមកធ្វើជាឧបករណ៍ដើម្បីបន្ធូរបន្ថយគំនិតតស៊ូបដិវត្តរបស់អ្នកទោសខ្លះ ។ ដូចជារូបខ្ញុំជាដើម ។

ខ្ញុំជាប់ឃុំឃាំងក្នុងគុកភ្នំពេញ អស់រយៈពេលបីខែទៀត ទើបត្រូវគេបញ្ជូនទៅធ្វើការកាត់ទោសសាជាថ្មី នៅចំពោះមុខតុលាការលើក ។ ក្នុងសវនាការរបស់តុលាការ ចៅក្រមជាជនជាតិបារាំង ប៉ុន្តែមេធាវីតែងតាំងជាជាតិខ្មែរ ។

ប្រហែលជាមកពីអ្នកទោសនយោបាយកើតជំងឺច្រើនពេក រកកន្លែងដាក់គ្មាន បានជាមេធាវីខ្មែរនាំទាមទារដោះលែងរូបខ្ញុំ ហេតុបានសំរេច ។

ក្រោយមកមិនបានប៉ុន្មានម៉ោងផង គេបាននាំខ្ញុំទៅជួបចៅហ្វាយគុកធំ ។ ចៅហ្វាយបាននិយាយពាក្យព្រមានខ្ញុំជាច្រើន ទើបចេញលិខិតបញ្ជាក់មួយសម្រាប់ឱ្យ ហើយដោះលែងខ្ញុំចេញពីមន្ទីរឃុំឃាំងឱ្យមានសេរីភាព ។

ខ្ញុំមានតែខោអាវមួយចង្កេះ និងក្រមាចាស់មួយ ដែលជាករបស់ទាហានគ្រួតចិត្តសប្បុរស ក្រៅពីនោះគ្មានប្រាក់កាស និងគ្មានអ្វីទាំងអស់ ។

ទីកោះរូបទូ ដែលទើបនឹងស្គាល់ជាលើកដំបូងនេះ ទីក្រុងធំពេញហាក់ដូចជាធំទូលាយណាស់ ។ ផ្សារមានមនុស្សអ៊ឹកធឹកណែនណាន់តាន់តាប់ រថយន្តធំខ្លាក់ខ្លែងដូចក្រឡាចត្រង្គ ។ ហាងលក់ទំនិញគ្រប់បែបយ៉ាងមានច្រើនហួសហេ ដាក់តាំងលក់សុទ្ធតែវត្ថុប្រណីត ។ ។ ខ្ញុំឃើញមនុស្សទាំងឡាយធ្វើដំណើរទៅមក ភាគច្រើនសុទ្ធតែមានទឹកមុខរីករាយញញឹមញញែម អត់ពីតែខ្ញុំម្នាក់ដែលគ្មានទីពំនាក់ស្នាក់អាស្រ័យ និងគ្មានស្គាល់នរណាម្នាក់សោះនៅក្នុងទីក្រុងនេះ ។

ខ្ញុំចេះតែដើរពាសវាលពាសកាលឥតទីដៅ រហូតរសៀលថ្ងៃជិតលិច ក៏មកដល់ភ្នំតូចមួយ ដែលមានចេតិយធំខ្ពស់ត្រដឹម និងព្រះវិហារតូចស្អាតនៅលើនោះ ។ ដោយឃើញទីអារាមខាងសភាពស្អាតបាត ណាមួយមិនដឹងជាត្រូវទៅដេកពួននៅឯណាផង ខ្ញុំក៏សំរេចចិត្តសំរាកនៅលើភ្នំតែម្ដង ។

ពេលយប់មកដល់ ខ្ញុំកាច់ស្លឹកឈើមួយបាច់យកមកបោសឥដ្ឋក្រោយសំយាបព្រះវិហារចំហៀងខាងត្បូង ហើយប្រះដេកទាំងស្រេកឃ្លានស្ទើរដាចពោះ ។ យប់ជ្រៅសន្សើមធ្លាក់រងារណ្តាំគ្លាយ ខ្ញុំអង្គុយផ្ទៀងក្រញូវខ្លួនក្នុងក្រមាចាស់ស្ដើងទាំងញាក់ញ័រ ប៉ុន្តែក្នុងចិត្តនៅតែសប្បាយរីករាយដូចបក្សីទើបរួចពីទ្រុង ព្រោះជិតពីរឆ្នាំមកហើយ ទើបតែ



ក្រីនេះទេ ដែលខ្ញុំបានដេកក្រៅគុកគ្មានខ្នោះជើង គ្មានអ្នកយាមចាំឃ្លាំមើល ។

មាន់រងាវជិតភ្លឺ ដោយអស់កម្លាំងពេក ខ្ញុំក៏លង់លក់ទៅ ។ មិនដឹងជាអស់រយៈពេលប៉ុន្មានម៉ោងទេ លុះភ្ញាក់ដឹងខ្លួនវិញ ស្រាប់តែឮស្នូរសំឡេងសត្វចាបខ្សៀវខ្សាវនៅលើចុងឈើ ហើយមេឃក៏ភ្លឺស្រាង ៗ ជាស្រេច ។ លុះខ្ញុំស្ទុះងើបឡើង ឃើញព្រះសង្ឃចំណាស់មួយអង្គកាន់អំបោស ឈរមើលមកខ្ញុំយ៉ាងយកចិត្តទុកដាក់ ។ ឃើញដូច្នោះខ្ញុំក៏លុតជង្គង់ថ្វាយបង្គំលោក ព្រះសង្ឃញញឹមស្ងួតបួត ហើយសាកសួរមកខ្ញុំ ។ ខ្ញុំឆ្លើយបណ្ដើរចូលទៅជិតលោកបណ្ដើរ ហើយសុំអំបោសបោសដីជំនួសព្រះសង្ឃអង្គវិញ ។ ព្រះសង្ឃឥតឃាត់ឃាំងអ្វីទេ លោកបណ្ដោយឲ្យខ្ញុំធ្វើកិច្ចការនេះតាមសំណូមពរ ប៉ុន្តែដោយដឹងថា ខ្ញុំជាជនជាតិឡាវ លោកក៏សួរជាភាសាថៃ ៖

- អាត្មាជឿថាឯងចេះស្ដាប់ភាសាថៃជាមិនខាន

- ខ្ញុំព្រះករុណាអាចស្ដាប់បានខ្លះ ។ ព្រោះភាសាថៃ និងឡាវប្រហាក់ប្រហែលគ្នា ( ខ្ញុំឆ្លើយបណ្ដើរ បោសបណ្ដើរ )

- ឯងគ្មានផ្ទះសំបែងទេឬ បានជាមកដេកនៅទីនេះអីចឹង ?...

- ខ្ញុំព្រះករុណា ត្រូវគេចាប់ខ្លួនចាប់ពីប្រទេសឡាវ យកមកដាក់គុកនៅកោះត្រឡាចអស់រយៈជាងពីរឆ្នាំមកហើយ ។ គេទើបនឹងដោះលែងខ្ញុំឲ្យមានសេរីភាពពីម្សិលមិញ ។ ព្រះសង្ឃងក់ព្រះកេសរយឺត ៗ ហើយមានពុទ្ធដីកា ៖

- កុដិរបស់អាចារ្យនៅខាងជើងព្រះវិហារ បន្តិចទៀតនឹងនៅរ ហូបបបាចុះ ។

បន្ទាប់ពីព្រះសង្ឃមិនទៅនៅផុត ខ្ញុំក៏ចាប់ផ្ដោសផ្ដិតនៅទៀតរហូ បរិវេណជុំវិញព្រះវិហារមានស្អាតបាតទាំងអស់ ។

ថ្ងៃនេះ ខ្ញុំដើរតម្រែកក្នុងទីក្រុងតបោះទៀត ដោយសញ្ជឹងគិត តើខ្ញុំត្រូវប្រកបការងារអ្វីដើម្បីរកប្រាក់ចិញ្ចឹមជីវិតមិនឱ្យដើរណើរទៅប្រទេស ឡាវវិញ ពើខ្ញុំគ្មានប្រាក់សំរាប់ធ្វើដើមទុនសោះ ហើយនេះភាសាខ្មែរ បន្តិចបន្តួចប្រើការពុំបាន ណាមួយពុំស៊ាំនឹងរបៀបរបបរស់នៅរបស់ប្រជ ជនក្នុងជាតិខ្មែរនោះឡើយ ។

នៅមិនសូវឆ្ងាយពីផ្ទះខ្ញុំនោះ មានផ្សារមួយធំដែលមានមនុស្ស ច្រើនកុះករណែនណាន់តាន់តាប់ ឈ្មួញលក់ដូរតាមហាងតូចៗ សុទ្ធតែជា ជនជាតិចិន ។ នៅក្នុងផ្សារមានជនជាតិវៀតណាមច្រើនដែរ រីឯជន ជាតិខ្មែរសុទ្ធតែកសិករពីចម្ការក៏ចុកកំប៉ុកជាកម្មករព្រែងជុំវិញ្ញ ។

នៅខាងត្បូងផ្សារ មានកំពង់ផែមួយ ដែលមានកប៉ាល់ និងក ណ្ដូតតូចធំចេញចូលឥតដាច់ ។ ហើយឃើញមានកម្មករប្រកបរបរលី សែងជាច្រើន ដែលសុទ្ធតែជាជនជាតិខ្មែរ ប្រកបដោយរូបរាងកាយមាំ មួន ។ ឃើញមានសកម្មភាពនៅទីនេះ ខ្ញុំចាប់ផ្ដើមនឹកឃើញភ្លាមថា ខ្ញុំ អាចរកការងារធ្វើបានហើយ ។

យប់នោះ ខ្ញុំត្រឡប់មកវត្តខ្មែរដេកនៅសំយាបព្រះវិហារដដែល វិញ ។ រហូតមកដល់ពេលនេះទើបខ្ញុំដឹងថា វត្តខ្ញុំតូចនេះ ឈ្មោះត្រូវ ពេញ ហើយវត្តនោះលើកំពូលភ្នំ មានឈ្មោះថាវត្តភ្នំ ។ មនុស្សនៅទី ក្រុងភ្នំពេញ ក៏ដូចជានៅតាមខេត្តនានាដែរ អ្នកណាក៏ធ្លាប់ស្គាល់វត្តភ្នំ ព្រោះវត្តភ្នំជានិមិត្តរូបនៃទីក្រុងភ្នំពេញ ពុំខុសពីចេតិយថាតលួង ជានិមិត្ត- រូបរបស់ទីក្រុងវៀងចន្ទន៍នោះទេ ។

ពេលខ្ញុំប្រះខ្លួនដេកបានមួយសន្ទុះ ស្រាប់តែលោកព្រះសង្ឃដែល នេះសាលាបចាំក្រោកនោះ និមន្តមកដល់ ។ លោកបានប្រគល់កន្ទេល ពូកមួយ ខ្នើយមួយ មុង សំពត់ចាស់មួយឱ្យខ្ញុំ ។ ខ្ញុំថ្វាយបង្គំសំដែង អំណរគុណចំពោះព្រះសង្ឃដោយក្ដីរំភើបត្រេកអរក្រៃលែង ។

ព្រះសង្ឃសប្បុរស មានគុណធម៌ការុញ្ញបូជនីយស្ថាន ក៏និមន្ត ត្រឡប់ទៅវិញ ។ កាយវិការរបស់ព្រះសង្ឃធ្វើឱ្យខ្ញុំនឹកឃើញដល់ នារីក្រមុំដែលបានផ្ដល់សំលៀកបំពាក់ដល់ខ្ញុំ កាលនៅក្នុងពន្ធនាគារ ។

រាត្រីនោះ ខ្ញុំដេកលក់ស្កប់ស្កល់ និង ប្រកបដោយផាសុកភាព យ៉ាងបរមសុខ ស្រៀបចំផ្លូវមហាសេដ្ឋីដេកក្នុងវិមានស្ដុកស្ដម្ភរបស់គេ ។

* * *